**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក**

សេចក្តីប្រកាសព័ត៌មាន

## «សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ពង្រឹងបន្ថែមនូវការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះកិច្ចសហប្រតិបត្តិការប្រកបដោយគុណភាពខ្ពស់ ក្នុងអំឡុងពេលចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវលើកទី៣ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ នៅរដ្ឋធានីប៉េកាំង»

តបតាមការអញ្ជើញរបស់**ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវលើកទី៣ (3rd BRF) សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ នៅរដ្ឋធានីប៉េកាំង។ មូលបទនៃកិច្ចប្រជុំនេះគឺ «**កិច្ចសហប្រតិបត្តិការខ្សែក្រវាត់ និងផ្លូវ ប្រកបដោយគុណភាពខ្ពស់៖ រួមគ្នាដើម្បីការអភិវឌ្ឍ និងវិបុលភាពរួម**»។

### ១. វេទិកាខ្សែក្រវាត់ និងផ្លូវលើកទី៣

ប្រមុខរដ្ឋ/រដ្ឋាភិបាល ចំនួន ២៣រូប ប្រទេសជាង ១៤០ និងអង្គការប្រមាណ ៣០ បានចូលរួមក្នុងវេទិកានេះ ដែលត្រូវបានរៀបចំឡើងស្របពេលជាមួយខួបលើកទី១០ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ (BRI)។ គំនិតផ្តួចផ្តើម BRI នេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រទេសកំពុងអភិវឌ្ឍ រួមទាំងកម្ពុជា ក្នុងនោះរួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគផ្ទាល់ពីបរទេស កំណើនសេដ្ឋកិច្ច ការធ្វើសមាហរណកម្មក្នុងតំបន់ និងសកលលោក និងការផ្លាស់ប្តូរប្រជាជន និងប្រជាជន។

**សម្តេចធិបតី** បានបញ្ជាក់ពីការគាំទ្រពេញទំហឹងរបស់កម្ពុជា និងការត្រៀមខ្លួនរួចជាស្រេចក្នុងការរួមគ្នាអនុវត្តនូវសកម្មភាពធំៗចំនួន ៨ ដែល**ប្រធានាធិបតី ស៊ី ជីនពីង** បានលើកឡើងក្នុងសុន្ទរកថាគន្លឹះក្នុងពិធីបើកវេទិកា រួមមាន៖ ការកសាងបណ្តាញតភ្ជាប់ពហុវិស័យខ្សែក្រវាត់ និងផ្លូវ ការ

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 1..
ទូរសារ : (855) 23 216 141, 023 213 ...
អ៊ីម៉ែល : mfaic@mfaic.gov.kh

គាំទ្រសេដ្ឋកិច្ចពិភពលោកបើកចំហ ការអនុវត្តកិច្ចសហប្រតិបត្តិការជាក់ស្តែង ការជំរុញការអភិវឌ្ឍបៃតង ការជំរុញនវានុវត្តន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការគាំទ្រការផ្លាស់ប្តូរប្រជាជន និងប្រជាជន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការខ្សែក្រវាត់ និងផ្លូវ ដែលឈរលើមូលដ្ឋាននៃសុចរិតភាព និងការពង្រឹងការកសាងស្ថាប័នសម្រាប់កិច្ចសហប្រតិបត្តិការខ្សែក្រវាត់ និងផ្លូវ ជាលក្ខណៈអន្តរជាតិ។

ក្នុងឱកាសចូលរួមវេទិកាខាងលើ **សម្តេចធិបតី** បានអញ្ជើញថ្លែងសុន្ទរកថា ដោយបានគូសបញ្ជាក់ពីសារសំខាន់នៃកំណើនសេដ្ឋកិច្ចឌីជីថល ដែលជាប្រភពថ្មីនៃកំណើន តាមរយៈការផ្តល់កាលានុវត្តន៍ភាពដ៏ពិសេសមួយដល់ប្រទេសនានា ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងគោលបំណងសម្រេចឱ្យបានពេញលេញនូវសក្តានុពលរបស់សេដ្ឋកិច្ចឌីជីថល **សម្តេចធិបតី** បានសង្កត់ធ្ងន់ពីសារសំខាន់នៃគោលនយោបាយ និងបទប្បញ្ញត្តិអំណោយផល ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់នវានុវត្តន៍ ការពារកម្មសិទ្ធិបញ្ញា និងលើកកម្ពស់អក្ខរកម្មឌីជីថល។ **សម្តេចធិបតី** បានអំពាវនាវឱ្យបង្កើនការផ្តល់មូលនិធិដល់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងប្រទេសកំពុងអភិវឌ្ឍ រួមមានការតភ្ជាប់ មជ្ឈមណ្ឌលទិន្នន័យ សន្តិសុខ ព្រមទាំងកត្តាជំរុញ និងថ្នាលសំខាន់ៗដទៃទៀត តាមរយៈក្របខ័ណ្ឌBRI។

**សម្តេចធិបតី** បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្លាស់ប្តូរពីគំរូសេដ្ឋកិច្ចប្រពៃណី ទៅជាសេដ្ឋកិច្ចឌីជីថលដែលមានភាពធន់ តាមរយៈការដាក់ចេញនូវគោលនយោបាយពាក់ព័ន្ធនឹងឌីជីថលមួយចំនួន។ **សម្តេចធិបតី** បានជំរុញឱ្យដៃគូសំខាន់ៗ ទាំងវិស័យសាធារណៈ និងឯកជន ស្វែងយល់ពីឱកាសដ៏ធំធេងដែលកម្ពុជាអាចផ្តល់ជូន ក្នុងវិស័យសេដ្ឋកិច្ចឌីជីថល។

ប្រធានវេទិកាបានដាក់ចេញនូវសេចក្តីថ្លែងការណ៍មួយ ដែលបង្ហាញពីលទ្ធផលប្រកបដោយផ្លែផ្កា និងសមិទ្ធផលគន្លឹះៗផងដែរ។

## ២.ជំនួបទ្វេភាគី

ក្នុងឱកាសចូលរួមវេទិកានេះ **សម្តេចធិបតី** បានជួបសម្តែងការគួរសម **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** និងជួបពិភាក្សាដាច់ដោយឡែកជាមួយ **ឯកឧត្តមនាយករដ្ឋមន្ត្រី លី ឈាង** និង**ឯកឧត្តម ឆាយ ឈី** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃការិយាល័យនយោបាយគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនីស្តចិន និងជាប្រធានការិយាល័យកិច្ចការទូទៅនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន ដើម្បីធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន។

**ភាគីទាំងពីរ**បានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍយ៉ាងខ្លាំងក្លានៃទំនាក់ទំនងកម្ពុជា-ចិន និងបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការត្បូងពេជ្រដែលផ្តោតលើវិស័យអាទិភាពចំនួន ០៦ និងការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន។

**សម្តេចធិបតី** និង**ប្រធានាធិបតី ស៊ី ជីនពីង** បានប្រកាសរួមគ្នាកំណត់យកឆ្នាំ២០២៤ ជាឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជនរវាងកម្ពុជានិងចិន។ ភាគីទាំងពីរបានឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ហើយភាគីចិនបានសន្យាលើកទឹកចិត្តទេសចរចិនមកទស្សនាកម្ពុជាឱ្យបានកាន់តែច្រើនឡើង។

**ភាគីទាំងពីរ**ក៏បានឯកភាពគ្នាពង្រឹងកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍថាមពលបៃតង និងបានស្វាគមន៍ការចុះហត្ថលេខាលើ «អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអភិវឌ្ឍវារីអគ្គិសនីបូមទឹកស្តុកទុកតាតៃលើ» ដែលនឹងរួមចំណែកដល់សន្តិសុខថាមពល និងការអភិវឌ្ឍថាមពលស្អាតនៅកម្ពុជា។

**ភាគីទាំងពីរ**បានឯកភាពគ្នាពន្លឿនការអភិវឌ្ឍ «ច្រករបៀងអភិវឌ្ឍន៍ឧស្សាហកម្ម» និង «ច្រករបៀងមច្ឆានិងអង្ករ» ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការឧស្សាហកម្ម និងកសិកម្មទ្វេភាគី និងធ្វើទំនើបកម្មវិស័យកសិកម្មនៅកម្ពុជា។ តបតាមសំណើរបស់កម្ពុជា ភាគីចិនបានឯកភាពនឹងជំរុញក្រុមហ៊ុនចិនមកវិនិយោគលើវិស័យអាទិភាពដែលផ្តល់ផលប្រយោជន៍រួម។

**ភាគីទាំងពីរ**វាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាក្រោមកិច្ចសហប្រតិបត្តិការខ្សែក្រវាត់ និងផ្លូវ ដូចជាផ្លូវល្បឿនលឿនភ្នំពេញ–ព្រះសីហនុ តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ។ **ភាគីទាំងពីរ**បានឯកភាពពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ។

**ភាគីទាំងពីរ** ក៏បានឯកភាពគ្នាបង្កើនបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ ជាពិសេស ក្នុងការប្រយុទ្ធប្រឆាំងនឹងល្បែងភ្នាល់ឆ្លងដែន ការជួញដូរមនុស្ស និងគ្រឿងញៀន ឧក្រិដ្ឋកម្មតាមអ៊ីនធឺណេត និងព័ត៌មានក្លែងក្លាយ។

ភាគីចិនបានបញ្ជាក់សាជាថ្មីនូវការគាំទ្រឥតងាករេចំពោះកម្ពុជា ក្នុងការជ្រើសរើសមាគ៌ាអភិវឌ្ឍន៍សមស្របតាមលក្ខខណ្ឌជាតិ។ **សម្តេចធិបតី** បានសម្តែងនូវអំណរគុណចំពោះជំនួយ និងការគាំទ្រ ដ៏ថ្លៃថ្លារបស់ចិន ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា។ **សម្តេចធិបតី** ក៏បានបញ្ជាក់សាជាថ្មីអំពីការប្រកាន់ខ្ជាប់ឥតងាករេរបស់កម្ពុជាចំពោះគោលនយោបាយចិនមួយ។ **ភាគីទាំងពីរ**បានបញ្ជាក់សាជាថ្មីអំពីការសហការគ្នាយ៉ាងជិតស្និទ្ធ និងការគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាតំបន់ និងពហុភាគី។

**សម្តេចធិបតី** និង**នាយករដ្ឋមន្ត្រី លី** បានធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការទ្វេភាគីចំនួន ១០ ក្នុងវិស័យនានា រួមមាន ការវិនិយោគ សមត្ថភាពផលិត ពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធឺណេត បរិវត្តកម្មឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងការអភិវឌ្ឍបៃតង។

**សម្តេចធិបតី** ក៏បានជួបសម្តែងការគួរសមដាច់ដោយឡែកជាមួយ**ឯកឧត្តម វ៉ូ វ៉ាន់ធឿង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង**ឯកឧត្តម ថងលុន ស៊ីសុលីត** ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

**សម្តេចធិបតី** និង**ប្រធានរដ្ឋ ធឿង** បានពិភាក្សាគ្នាអំពីវិធីនានា ដើម្បីពង្រឹងចំណងមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ទៅវិញទៅមក ក្នុងវិស័យសំខាន់ៗ រួមមានពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ ការតភ្ជាប់ ការពារជាតិ និងសន្តិសុខ និងការអប់រំ។ **ថ្នាក់ដឹកនាំទាំងពីរ**ក៏បានឯកភាពគ្នារក្សាកិច្ចសន្ទនាកម្រិតខ្ពស់រវាងប្រទេសទាំងពីរ។ **ថ្នាក់ដឹកនាំទាំងពីរ** បានគូសបញ្ជាក់ពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការត្រីភាគីជាមួយប្រទេសឡាវ ក្នុងការលើកកម្ពស់ការតភ្ជាប់ និងការអភិវឌ្ឍរួមលើវិស័យនានា ដូចជាពាណិជ្ជកម្ម ទេសចរណ៍ និង ឧស្សាហកម្ម ជាដើម។

**សម្តេចធិបតី** និង**ប្រធានរដ្ឋ ថងលុន** បានពិភាក្សាគ្នាអំពីការធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យជាច្រើនដូចជា នយោបាយ ការពារជាតិ ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ ថាមពល ការតភ្ជាប់ វប្បធម៌ និងការអប់រំ។ **ថ្នាក់ដឹកនាំទាំងពីរ** ក៏បានឯកភាពគ្នានឹងពង្រឹងបន្ថែមទៀត នូវភាពជាដៃគូយុទ្ធសាស្ត្រយូរអង្វែង និងគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងឡាវ ដើម្បីជាប្រយោជន៍ទៅវិញទៅមកដល់ប្រទេស និងប្រជាជនទាំងពីរ។ **ថ្នាក់ដឹកនាំទាំងពីរ** បានសង្កត់ធ្ងន់ពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការត្រីភាគីជាមួយភាគីវៀតណាម ជាពិសេសក្នុងការអភិវឌ្ឍទេសចរណ៍រួមគ្នា (ប្រទេសបី គោលដៅតែមួយ) ដែលជាគំនិតផ្តួចផ្តើមរបស់ **សម្តេចធិបតី** ។ **ថ្នាក់ដឹកនាំទាំងពីរ** ក៏បានបញ្ជាក់សាជាថ្មីនូវការគាំទ្រគ្នាទៅវិញទៅមក ក្នុងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ។

ក្នុងអំឡុងពេលស្នាក់នៅ ក្នុងទីក្រុងប៉េកាំង **សម្តេចធិបតី** ក៏បានជួបជាមួយក្រុមហ៊ុនចិនធំៗមួយចំនួន ដែលកំពុងវិនិយោគលើវិស័យធនាគារ ថាមពល សំណង់ វិស្វកម្ម និងអចលនទ្រព្យ នៅកម្ពុជា។ **សម្តេចធិបតី** បានជំរុញឱ្យក្រុមហ៊ុនចិនទាំងនោះ ពង្រីកការវិនិយោគរបស់ខ្លួននៅកម្ពុជា ហើយក្រុមហ៊ុនទាំងនោះ បានសម្តែងការនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល ដែលបានគាំទ្រសកម្មភាពធុរកិច្ចរបស់ខ្លួន៕

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣